# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីទំហំ ៨.៨៩២ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៤ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៨៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំកោះខ្មែរ ឃុំក្បាលដំរី និងឃុំសណ្តាន់ ស្រុកសំបូរ ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកាលេខ ១៤៤០ចណ.ក្រច ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ របស់អភិបាលខេត្ត និងជាប្រធានគណៈកម្មការគ្រប់គ្រងដីរដ្ឋខេត្ត ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី ទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អិន. ខេ. អេគ្រី (ខេមបូឌា) លីមីធីត (N. K. AGRI (CAMBODIA) LIMITED)

ស្ថិតនៅក្នុងឃុំកោះខ្ញែរ ឃុំក្បាលដំរី ឃុំសំបូរ និងឃុំសណ្ដាន់ ស្រុកសំបូរ ខេត្តក្រចេះ




| N | X | Y | N | X | Y |
|---|---|---|---|---|---|
| 1 | 614970 | 1421006 | 16 | 616188 | 1418072 |
| 2 | 614733 | 1420426 | 17 | 617039 | 1416086 |
| 3 | 614285 | 1419329 | 18 | 619982 | 1420984 |
| 4 | 614905 | 1418707 | 19 | 619593 | 1419557 |
| 5 | 614956 | 1419795 | 20 | 620603 | 1418664 |
| 6 | 615238 | 1419316 | 21 | 621479 | 1418878 |
| 7 | 615754 | 1418800 | 22 | 622867 | 1419569 |
| 8 | 615832 | 1419738 | 23 | 623001 | 1420972 |
| 9 | 615183 | 1419871 | 24 | 623770 | 1413436 |
| 10 | 615048 | 1420498 | 25 | 623284 | 1413689 |
| 11 | 615259 | 1420996 | 26 | 622407 | 1413634 |
| 12 | 617368 | 1414051 | 27 | 622248 | 1410877 |
| 13 | 618056 | 1414725 | 28 | 621912 | 1410763 |
| 14 | 618440 | 1418019 | 29 | 621896 | 1410231 |
| 15 | 618877 | 1418946 | 30 | 622138 | 1410051 |

លេខ:......
បានឃើញ និង ស្នើសុំការគាំទ្រ
ឯកឧត្តមអភិបាលនៃគណៈអភិបាល ...
ស្ទឹង ថ្ងៃទី...... ខែ...... ឆ្នាំ២០...

ហេង-ស៊ុ...

លេខ:......
បានឃើញ និងសូមគោរពជូន
ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យនិងសម្រេច
ក្រចេះ ថ្ងៃទី...... ខែ...... ឆ្នាំ២០...
ប្រធានមន្ទីរ កសិកម្មខេត្ត

គុយ. ហ្វូត

លេខ:......
បានឃើញ និងសូមគោរពជូន
ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យនិងសម្រេច
ក្រចេះ ថ្ងៃទី...... ខែ...... ឆ្នាំ២០...
ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុ...

អ៊ាន-ស៊ុ...

លេខ:......
បានឃើញ និងឯកភាព
ក្រចេះ ថ្ងៃទី...... ខែ...... ឆ្នាំ២០...
អភិបាលខេត្ត នៃគណៈអភិបាលខេត្តក្រចេះ

ខាំ-ភឿន